# ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ គ្រឹះស្ថានហិរញ្ញវត្ថុ មិនមែនជារបស់រដ្ឋនោះទេ




ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧នេះ បានបញ្ជាក់ថា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ គ្រឹះស្ថានហិរញ្ញវត្ថុ មិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទាន ដែលប្រជាពលរដ្ឋមួយចំនួន ជាពិសេស នៅតំបន់ជនបទ តែងតែច្រឡំថាជារបស់រដ្ឋនោះ គឺមិនមែនជារបស់រដ្ឋនោះទេ។

ក្នុងឱកាសអញ្ជើញជាអធិបតី ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា វត្តព្រៃកប្រា សង្កាត់ព្រៃកប្រា ខណ្ឌច្បារអំពៅ នៅព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍

បានអំពាវនាវ ដល់អ្នកពាក់ព័ន្ធ និងតុលាការ ត្រូវចាត់វិធានការ តាមផ្លូវច្បាប់ ចំពោះជនណា ឬគណបក្សនយោបាយណា ដែលដើរ ឃោសនាថា នឹងលុបបំណុលប្រជាពលរដ្ឋជំពាក់ធនាគារចោលទាំងអស់ បើសិនខ្លួនឈ្នះឆ្នោត ។ សម្តេចបានបញ្ជាក់ទៀតថា រាល់មីក្រូហិរញ្ញវត្ថុទាំងអស់ ទោះបីមានឈ្មោះអ្វីក៏ដោយ មិនមែនជារបស់រដ្ឋទេ ព្រោះកន្លងទៅមានការភ័ណ្ឌច្រឡំថា មីក្រូហិរញ្ញវត្ថុឈ្មោះនេះ ឈ្មោះនោះ ជារបស់រដ្ឋ ហើយថា រដ្ឋតែងតែទៅទារការប្រាក់ រឹបអូសផ្ទះ រឹបអូសដី។

យោងតាមសេចក្តីថ្លែងការណ៍រួម របស់ ក្រសួងសេដ្ឋកិច្ច និងធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ បានឲ្យដឹងថា ដើម្បីចៀសវាងការយល់ច្រឡំ ក្រសួងសេដ្ឋកិច្ច និងធនាគារជាតិស្រាយបំភ្លឺថា ៖ ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថាននមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិឥណទានជនបទ ទាំងអស់ ដែលទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មពីធនាគារជាតិ នៃកម្ពុជា គឺជាគ្រឹះស្ថានដែលកាន់កាប់ និងគ្រប់គ្រង ដោយឯកជន មិនមែនជារបស់រដ្ឋឡើយ។ គ្រឹះស្ថានទាំងនេះ គឺជាក្រុមហ៊ុនឯកជន ដែលត្រូវតែស្វែងរកប្រាក់ចំណេញ សម្រាប់ទ្រទ្រង់និរន្តរភាព ប្រតិបត្តិការរបស់ខ្លួន។

សេចក្តីថ្លែងការណ៍បន្តថា ពលរដ្ឋដែលខ្ចីប្រាក់ពី ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទាន ជនបទ ត្រូវមានកាតព្វកិច្ចសងប្រាក់វិញ ។

ដោយឡែក ធនាគារអភិវឌ្ឍន៍ជនបទ គឺជាធនាគាររបស់រដ្ឋតែមួយគត់ ដែលបានរួមចំណែកផ្តល់ប្រាក់កម្ចីដល់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋ ដែលជំពាក់ប្រាក់ធនាគារនេះ ត្រូវមានកាតព្វកិច្ចសង់ប្រាក់ មកធនាគារវិញដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងសេដ្ឋកិច្ច និងធនាគារជាតិ សង្ឃឹមនិងជឿជាក់ថា អាជ្ញាធរមូលដ្ឋាន និងសហការចូលរួមផ្សព្វផ្សាយ និងអប់រំពលរដ្ឋ កុំឲ្យយល់ច្រលឡំថា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណជនបទ ជារបស់រដ្ឋ និងដើម្បីចៀសវាង ការឃោសនា ភូតកុហករបស់ ជនអគតិបន្តទៀត។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ធនាគារជាតិ នៃ កម្ពុជា

## សេចក្តីថ្លែងការណ៍រួម
## រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា

នាពេលកន្លងមកនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួន ជាពិសេស នៅតំបន់ជនបទ តែងតែមានការយល់ច្រឡំថា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទ ជាគ្រឹះស្ថានរបស់រដ្ឋ ។

ដើម្បីចៀសវាងការយល់ច្រឡំខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សូមបំភ្លឺជូនសាធារណជនជ្រាបថា ៖

១. ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទទាំងអស់ ដែលទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មពីធនាគារជាតិនៃកម្ពុជា គឺជាគ្រឹះស្ថានដែលកាន់កាប់ និងគ្រប់គ្រងដោយឯកជន មិនមែនជារបស់រដ្ឋឡើយ ។

២. គ្រឹះស្ថានទាំងនោះ គឺជាក្រុមហ៊ុនឯកជន ដែលត្រូវតែស្វែងរកប្រាក់ចំណេញសម្រាប់ទ្រទ្រង់និរន្តរភាពប្រតិបត្តិការរបស់ខ្លួន ។

៣. ប្រជាពលរដ្ឋដែលខ្ចីប្រាក់ពី ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទ ត្រូវមានកាតព្វកិច្ចសងប្រាក់កម្ចីវិញ ។ ការមិនគោរពកាតព្វកិច្ចសងប្រាក់កម្ចី

វិញ អាចប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់អ្នកខ្ចីប្រាក់ និងមិនអាចទទួលបានប្រាក់កម្ចីថ្មីបន្ថែមទៀតសម្រាប់បំពេញតម្រូវការនាពេលក្រោយ ។

៤. ធនាគារអភិវឌ្ឍន៍ជនបទ គឺជាធនាគាររបស់រដ្ឋតែមួយគត់ ដែលបានរួមចំណែកផ្តល់ប្រាក់កម្ចីដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ព្រមទាំងគាំទ្រការផ្តល់ប្រាក់កម្ចីដល់វិស័យកសិកម្ម វិស័យកសិ-ឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យម និងផ្តល់ប្រាក់កម្ចីបន្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋដែលជំពាក់ប្រាក់ធនាគារនេះ ត្រូវមានកាតព្វកិច្ចសងប្រាក់មកធនាគារវិញ ។

៥. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សង្ឃឹមនិងជឿជាក់ថា អាជ្ញាធរមូលដ្ឋាន នឹងសហការចូលរួមផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋ កុំឱ្យយល់ច្រឡំថា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទ ជារបស់រដ្ឋ និងដើម្បីចៀសវាងការឃោសនាភូតកុហករបស់ជនអគតិបន្តទៀត ។

៦. ជនណាដែលដើរឃោសនាបោកប្រាស់ប្រជាពលរដ្ឋអំពីបញ្ហាលុបបំណុល នឹងត្រូវទទួលទោសតាមផ្លូវច្បាប់ជាធរមាន ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៧